002/19-09-2007/ECCC/TC
E254/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 01 / 2013
ម៉ោង (Time/Heure): 08:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម យូរ ឧត្តរា |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៣ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

## សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើសុំថតខ្សែអាត់សំឡេង និង/ឬ វីដេអូ នៅពេល អៀង សារី ស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន
អៀង សារី

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Jaques VERGÈS
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

1. មេធាវីការពារក្តី អៀង សារី ("មេធាវីការពារក្តី") បានស្នើសុំឱ្យខ្លួនមានសិទ្ធិថតខ្សែអាត់សំឡេង និង/ឬ វីដេអូ អៀង សារី ("ជនជាប់ចោទ") នៅក្នុងបន្ទប់ឃុំខ្លួនដែលស្ថិតនៅពីក្រោមសាលសវនាការដែលជាទីកន្លែងជនជាប់ចោទរូបនេះចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី នាពេលបច្ចុប្បន្ន[1]។ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើសុំរបស់ក្រុមមេធាវីការពារក្តី ដោយមានសំអាងហេតុដូចខាងក្រោម។

## ២. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានតម្កល់ការយល់ឃើញនាពេលកន្លងមករបស់ខ្លួនថា ជនជាប់ចោទមានសម្បទាក្នុងការចូលរួមសវនាការ[2]។ អនុលោមតាមវិធាន ៨១(៥) នៃ វិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា ជន ជាប់ចោទ អាចត្រូវបានបង្គាប់ឱ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈមធ្យោបាយ សោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការបាន ហើយអង្គជំនុំជម្រះក៏បានចេញសេចក្តីជូនដំណឹងថា អង្គជំនុំជម្រះអាចសម្រេចឱ្យប្រើប្រាស់មធ្យោបាយនេះ នៅពេលដែលជនជាប់ចោទត្រូវបានយល់ឃើញថា មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ ប៉ុន្តែ នៅពេលដែលវត្តមានរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការ អាចនឹងផ្ទុយពីស្ថានភាពផ្នែកវេជ្ជសាស្ត្ររបស់គាត់ និង/ឬ ផ្ទុយពីការប្រព្រឹត្តទៅឱ្យបានរាប់រហ័សនៃការជំនុំជម្រះនោះ[3]។ អង្គជំនុំជម្រះសាលាដំបូងក៏បានច្រានចោលសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តីដែល បានលើកឡើងថា ជនជាប់ចោទគួរត្រូវបានអនុញ្ញាតឱ្យថតវីដេអូនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ ដោយហេតុថាការថតវីដេអូពុំចាំបាច់ធ្វើឡើងដើម្បីធានាថា ជនជាប់ចោទត្រូវបានតាមដានបានយ៉ាងសមស្របនោះទេ និងដោយសារថាបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ តែងតែផ្តល់លទ្ធភាពឱ្យសមាជិករបស់ក្រុមមេធាវីការពារក្តី និងអង្គភាពពេទ្យ ប្រចាំនៅ អ.វ.ត.ក ចេញចូលបានគ្រប់ពេលវេលាទាំងអស់[4]។

3. នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ជនជាប់ចោទបានជូនដំណឹងដល់អង្គជំនុំជម្រះថា ជនជាប់ ចោទមានបំណងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ក្នុងអំឡុងពេលស្តាប់សក្ខីកម្មសាក្សី ដោយខ្លួនពុំចង់ចូលរួម

---

[1] សារណារបស់ អៀង សារី ស្តីពីច្បាប់ដែលអនុញ្ញាតឱ្យថតខ្សែអាត់សំឡេង និង/ឬ វីដេអូរបស់គាត់នៅក្នុងបន្ទប់ឃុំខ្លួន ឯកសារលេខ E254/1 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ("សារណារបស់ក្រុមមេធាវីការពារក្តីស្តីពីការថតខ្សែអាត់សំឡេង និង/ឬ វីដេអូ")។

[2] សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ឯកសារលេខ E238/9 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើសម្បទា")។

[3] សេចក្តីសម្រេចលើសម្បទា កថាខណ្ឌ ៣៧។

[4] សេចក្តីសម្រេចលើសម្បទា កថាខណ្ឌ ៣៦។

នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការឡើយ[5] ។ ទោះបីជាយ៉ាងនេះក្តី នៅមុនពេលកិច្ចដំណើរការនីតិវិធីបានចាប់ផ្តើមនៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ គ្រូពេទ្យមួយរូបក្នុងចំណោមគ្រូពេទ្យដែលមានភារកិច្ចពិនិត្យ ព្យាបាល និង ថែទាំជនជាប់ចោទគឺវេជ្ជបណ្ឌិត ឈៀ គន្ធារី បានរាយការណ៍ថា ស្ថានភាពរូបកាយរបស់ជនជាប់ចោទ “មិនល្អ” នោះទេ។ គ្រូពេទ្យរូបនេះបានផ្តល់អនុសាសន៍ថា ជនជាប់ចោទគួរនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងគួរចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការពីទីនោះ ពីព្រោះថា ការចូលរួមតាមរបៀបដូច្នេះអាចអនុញ្ញាតឱ្យគ្រូពេទ្យព្យាបាលមានលទ្ធភាពតាមដានស្ថានភាពសុខភាពរបស់ជនជាប់ចោទបាន[6]។ ផ្អែកលើមូលដ្ឋាននេះហើយ និងអនុលោមតាមវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ដែលបញ្ញត្តិទុករួចជាស្រេចថា អង្គជំនុំជម្រះអាចបង្គាប់ឱ្យជនជាប់ចោទចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈមធ្យោបាយសោតទស្សន៍សមស្របបាន ទើបអង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ដូច្នេះ [7] ។ អង្គជំនុំជម្រះក៏សម្រេចច្រានចោលសំណើសុំរបស់ក្រុមមេធាវីការពារក្តីដែលស្នើសុំថតរូបភាពវីដេអូជនជាប់ចោទដោយផ្អែកបន្ថែមទៀតលើមូលដ្ឋានថា អង្គជំនុំ-ជម្រះនឹងផ្អែកលើការសង្កេតផ្នែកវេជ្ជសាស្ត្រលើស្ថានភាពរបស់ជនជាប់ចោទដែលបានធ្វើឡើងដោយក្រុមគ្រូពេទ្យ[8]។

4. នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីបានជូនដំណឹងដល់អង្គជំនុំជម្រះថា មន្ត្រីគ្រប់គ្រងសំណុំរឿងរបស់ខ្លួនកំពុង “ធ្វើកំណត់ហេតុ” នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយក្រុមមេធាវីការពារក្តីនឹងដាក់កំណត់ហេតុប្រចាំថ្ងៃស្តីពីការសង្កេតរបស់ខ្លួនលើស្ថានភាពរបស់ជនជាប់ចោទ [9] ។ ក្រុមមេធាវីការពារក្តីអះអាងថា ការធ្វើដូច្នេះគឺ “ស្របទៅនឹងអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីម្សិលមិញ” និងអាចទំនងផ្តល់ជាភស្តុតាងអំពីខ្លឹមសារនៃកិច្ចសន្ទនាឆ្លើយឆ្លងជាមួយនឹងគ្រូពេទ្យដែលមានភារកិច្ចពិនិត្យព្យាបាល និងថែទាំជនជាប់ចោទ [10] ។ ទោះបីជាគ្រូពេទ្យបានចេញរបាយការណ៍ស្តីពីការតាមដាននៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ដោយផ្តល់អនុសាសន៍ថា ជនជាប់ចោទគួរចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការក៏ដោយ ក៏ក្រុមមេធាវីការពារក្តីនៅតែស្នើឡើងដដែល

---

[5] ការដកហូតលិខិតលះបង់សិទ្ធិរបស់លោក អៀង សារី ក្នុងការមានវត្តមាន ឯកសារលេខ E237/2 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២។ *សូមមើលផងដែរ* ការជូនដំណឹងរបស់ អៀង សារី អំពីការដកពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងការធ្វើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ឯកសារលេខ E249 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២។

[6] កំណត់ហេតុសុខភាពមុនពេលសវនាការ ឯកសារសម្ងាត់បំផុតលេខ E1/147.2 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២។

[7] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ២ ទំព័រ ១៧-២០។

[8] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ៤-៥, ១៣-១៤, ២១, ២៧-២៨។

[9] ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ២។

[10] ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ២។

ដោយហេតុថា គ្រូពេទ្យដែលមានភារកិច្ច ពិនិត្យ ព្យាបាល និងថែទាំជនជាប់ចោទ "យល់ឃើញថាវាពិបាកប្រាប់ថាតើ ជនជាប់ចោទមានលទ្ធភាពអាចតាមដានកិច្ចដំណើរការនីតិវិធីបានដែរ ឬក៏អត់នោះ"[11]។ ក្រោយមក នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីបានចែកចាយសេចក្តីសង្កេតរបស់មន្ត្រីគ្រប់គ្រងសំណុំរឿងរបស់ខ្លួនលើជនជាប់ ចោទ ដែលបានធ្វើឡើងមុននេះមួយថ្ងៃ[12]។

5. ក្រោយមកទៀត ក្រុមមេធាវីការពារក្តីបានចែកចាយសេចក្តីសង្កេតជាលាយលក្ខណ៍អក្សរ បន្ថែមស្តីពីស្ថានភាពសុខភាពរបស់ជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ចាប់ពីថ្ងៃទី ០៥ និងថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២។ ករណីនេះបញ្ជាក់ឱ្យឃើញថា ក្រុមមេធាវីការពារក្តីបានថតខ្សែអាត់សំឡេងបានចំនួន ០៩ ខ្សែអាត់ នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២ និង ថតខ្សែអាត់សំឡេងចំនួន ១១ ខ្សែអាត់ នៅថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១២[13]។ អង្គជំនុំជម្រះបានទទួលរបាយការណ៍វេជ្ជសាស្ត្រពីគ្រូពេទ្យដែលមានភារកិច្ចពិនិត្យ ព្យាបាល និង ថែទាំជនជាប់ចោទនៅរាល់មុនពេលកិច្ចដំណើរការនីតិវិធីបានចាប់ផ្តើមនៅក្នុងថ្ងៃនីមួយៗ[14]។

6. នៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះបានបង្គាប់ក្រុមមេធាវីការពារក្តីឱ្យបញ្ឈប់ការថតជនជាប់ចោទ រួមទាំងការថតកិច្ចសន្ទនាឆ្លើយឆ្លងជាមួយនឹងគ្រូពេទ្យផងដែរ។ នៅក្នុងករណីដែលជនជាប់ចោទមានបំណងតវ៉ាថា ការថតសម្លេងរបស់ជនជាប់ចោទនៅក្នុងបន្ទប់ឃុំ ខ្លួនខាងក្រោមសាលសវនាការគឺចាំបាច់ ឬសមស្របនោះ អង្គជំនុំជម្រះស្នើឱ្យមានការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានហាមឃាត់ការថត ឬការធ្វើការសង្កេតបន្ថែមណាមួយ រហូតដល់ពេលអង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឱ្យអនុវត្តដូច្នេះ[15]។ អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២

---

[11] ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ២។ *សូមមើល* កំណត់ហេតុសុខភាពមុនពេលសវនាការថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារសម្ងាត់បំផុតលេខ E1/148.2 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២។

[12] តារាងពេលវេលានៃការសង្កេតលើលទ្ធភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងចូលរួមក្នុងការការពារក្តីរបស់គាត់ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E248/2.1 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២។

[13] តារាងពេលវេលានៃការសង្កេតលើលទ្ធភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងចូលរួមក្នុងការការពារក្តីរបស់គាត់ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E248.1 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២។ តារាង ពេលវេលានៃការសង្កេតលើលទ្ធភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងចូលរួមក្នុងការ ការពារក្តីរបស់គាត់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E248/1.1 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២។

[14] កំណត់ហេតុសុខភាពមុនពេលសវនាការថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារសម្ងាត់បំផុតលេខ E1/149.2 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ និងកំណត់ហេតុសុខភាពមុនពេលសវនាការថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារសម្ងាត់បំផុតលេខ E1/148.2 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២។

[15] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង "កម្មវត្ថុ៖ លិខិតរបស់ អៀង សារី ឆ្លើយតបទៅនឹងរបាយការណ៍មកពីមន្ទីរឃុំឃាំង" ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២។

ដោយបានតម្កល់ការហាមឃាត់ និងអញ្ជើញឱ្យដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរស្តី ពីការអនុញ្ញាតឱ្យថតខ្សែអាត់សំឡេង ការថតវីដេអូ ឬការធ្វើសេចក្តីសង្កេតទុកជា ភស្តុតាងដោយក្រុមមេធាវីការពារក្តី[16]។ ក្រុមមេធាវីការពារក្តីបានដាក់សេចក្តីសន្និដ្ឋានជា លាយលក្ខណ៍អក្សរនៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ហើយការិយាល័យសហព្រះរាជអាជ្ញា បានដាក់ចម្លើយតបនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២[17]។

7. ក្រោយពីបានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះសាលាដំបូង តាមសេចក្តីបង្គាប់រួចរាល់ហើយនោះ និងទោះបីជាបញ្ហានេះនៅរង់ចាំការដោះស្រាយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅឡើយក៏ដោយ នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១២ ក្រុមមេធាវីការពារ ក្តីបានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចនាពេលមុនៗរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានហាមឃាត់ក្រុមមេធាវីការពារក្តី មិនឱ្យថតវីដេអូចំពោះជនជាប់ចោទនៅក្នុង បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ[18]។

## ៣. សារណា

8. មេធាវីការពារក្តីអះអាងថា ខ្លួនមានសិទ្ធិធ្វើកំណត់ត្រាតាមរយៈការថតជាខ្សែអាត់សំឡេង និង/ឬវីដេអូ អំពីជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ មេធាវីការពារក្តី បានអះអាងថា “ការថតជាខ្សែអាត់សំឡេង/វីដេអូ គឺជាមធ្យោបាយប្រសើរបំផុត និងបង្កការរំខានតិចតួចបំផុតនៃការធ្វើកំណត់ហេតុ ដែលត្រឹមត្រូវ និងដែលអាចផ្ទៀងផ្ទាត់បានសម្រាប់ ការពិនិត្យមើលឡើងវិញលើបណ្តឹងសាទុក្ខអំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួម សវនាការ[19]។

---

[16] ដីកាបង្គាប់ឱ្យដាក់សារណា ឯកសារលេខ E254 ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២។

[17] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សារណារបស់ អៀង សារី ស្តីពីច្បាប់ដែលអនុញ្ញាតឱ្យគាត់ថតខ្សែអាត់ សំឡេង និង/ឬវីឌីអូនៅក្នុងបន្ទប់ខាងក្រោមសាលសវនាការ” ឯកសារលេខ E254/2 ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ (“ចម្លើយតបរបស់សហព្រះរាជអាជ្ញា”)។

[18] បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសិទ្ធិរបស់គាត់មិនឱ្យមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឱ្យថតវីដេអូលើរូបគាត់នៅក្នុងបន្ទប់ឃុំខ្លួន ខាង ក្រោមសាលសវនាការ ឯកសារលេខ E238/9/1/1 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២។ *សូមមើលផងដែរ* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលា ដំបូងទាក់ទងនឹងទម្រង់នៃការចូលរួម និងការថតវីឌីអូនៅក្នុងបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ ឯកសារលេខ E238/9/ 1/2 ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣។ និង សារណាតបរបស់ អៀង សារី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់គាត់ជំទាស់នឹងសេចក្តីសម្រេចដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសិទ្ធិរបស់គាត់ដើម្បីមានវត្តមាននៅក្នុងបន្ទប់សវនាការ និងហាមឃាត់មិនឱ្យមានការថតវីដេអូចំពោះរូបគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ឯកសារលេខ E238/9/1/3 ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣។

[19] សារណារបស់មេធាវីការពារក្តីស្តីពីការថតខ្សែអាត់សំឡេង និង/ឬវីដេអូ កថាខណ្ឌ ៧។

9. មេធាវីការពារក្តីអះអាងបន្ថែមថា សិទ្ធិក្នុងការធ្វើកំណត់ត្រាអំពីការសង្កេតលើលោក អៀង សារី គឺជាផ្នែកមួយនៃសិទ្ធិរបស់លោក ក្នុងការរៀបចំការការពារខ្លួន និងក៏ជាកាតព្វកិច្ចរបស់មេធាវីការពារក្តីចំពោះកូនក្តីរបស់ខ្លួនដែរ[20]។ ដោយផ្អែកទៅលើសេចក្តីសម្រេចមួយរបស់អង្គ-បុរេជំនុំជម្រះនៃ អ.វ.ត.ក មេធាវីការពារក្តីអះអាងថា ការបដិសេធមិនឲ្យមេធាវីការពារក្តីមានសិទ្ធិធ្វើកំណត់ត្រាជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ គឺជាការបដិសេធមិនឲ្យមេធាវីការពារក្តីមានមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន[21]។ មេធាវីការពារក្តីក៏បានអះអាងផងដែរថា មេធាវីការពារក្តីកំពុងត្រូវបានបដិសេធមិនឲ្យរកភ័ស្តុតាងដោះបន្ទុក[22]។ មេធាវីការពារក្តីអះអាងទៀតថា អនុលោមតាមវិធាន ២១(២) នៃ វិធានផ្ទៃក្នុង អ.វ.ត.ក ការកម្រិតណាមួយទៅលើសិទ្ធិក្នុងការថតខ្សែអាត់សំឡេង និង/ឬ វីដេអូ ជនជាប់ចោទត្រូវតែមានភាពសមាមាត្រ។ មេធាវីការពារក្តីស្នើឡើងនូវជម្រើសផ្សេងចំពោះការ ផ្សព្វផ្សាយជាសាធារណៈអំពីជនជាប់ចោទ នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដូចជាការផ្តល់នូវខ្សែអាត់ថតសំឡេងទាំងនេះរាល់ថ្ងៃជូនអង្គជំនុំជម្រះ ដោយរក្សានូវភាពសម្ងាត់[23]។

10. សហព្រះរាជអាជ្ញា បានឆ្លើយតបថា ក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ហាមឃាត់ភាគីនានាមិនឲ្យចាត់ធ្វើការស៊ើបអង្កេតទាំងឡាយដែលមានគោលបំណងប្រមូលភ័ស្តុតាងនោះឡើយ[24]។ ប្រសិនបើគ្រូពេទ្យព្យាបាលជនជាប់ចោទត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ សកម្មភាពរបស់មេធាវីការពារក្តីអាចត្រូវបានបកស្រាយថាជាការជ្រៀតជ្រែកសាក្សីទាំងនោះ[25]។ សហព្រះរាជអាជ្ញា អះអាងបន្ថែមទៀតថា ខ្សែអាត់ថតសំឡេង និង/ ឬវីដេអូ របស់មេធាវីការពារក្តីមិនអាចទទួលយកជាភ័ស្តុតាងបានឡើយ[26]។ សហព្រះរាជ- អាជ្ញាឆ្លើយតបថា ប្រតិចារឹកប្រចាំថ្ងៃ និងឯកសារនានានៅក្នុងសំណុំរឿងគឺគ្រប់គ្រាន់ដើម្បី ធ្វើកំណត់ត្រាឲ្យបានគ្រប់គ្រាន់[27]។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីខ្សែអាត់ថត

---

[20] សារណារបស់មេធាវីការពារក្តីស្តីពីការថតខ្សែអាត់សំឡេង និង/ឬវីដេអូ កថាខណ្ឌ ៧។

[21] សារណារបស់មេធាវីការពារក្តីស្តីពីការថតខ្សែអាត់សំឡេង និង/ឬវីដេអូ ទំព័រ ១ និង កថាខណ្ឌ៩-១១ ដោយផ្អែកលើសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/វីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ឯកសារ A371/2/12 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ("សាលដីការបស់ អ.ប.ជ ស្តីពីការថតខ្សែអាត់សំឡេង និង/ឬវីដេអូ") ជាពិសេស កថាខណ្ឌ ៣៥, ៣៩។

[22] សារណារបស់មេធាវីការពារក្តីស្តីពីការថតខ្សែអាត់សំឡេង និង/ឬវីដេអូ ទំព័រ ១ និងកថាខណ្ឌ ១២។

[23] សារណារបស់មេធាវីការពារក្តីស្តីពីការថតខ្សែអាត់សំឡេង និង/ឬវេដេអូ ទំព័រ ១ និងកថាខណ្ឌ ២៣។

[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧។

[25] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨។

[26] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០។

[27] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤។

សំឡេង និង/ឬវីដេអូនោះ គឺជាសេចក្តីសម្រេចពាក់ព័ន្ធនឹងកាលៈទេសៈផ្សេងគ្នា [28] ។ ទាក់ទិន នឹងវិធាន ២១(២) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាបដិសេធថា ការស្នើសុំថតខ្សែអាត់ សំឡេង និង/ឬវីដេអូនោះ គឺជាសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយ យុត្តិធម៌[29]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាស្នើអង្គជំនុំជម្រះកុំអនុញ្ញាតឱ្យភាគីចាត់ធ្វើការ ស៊ើបអង្កេតនានា និងរំឭកអង្គជំនុំជម្រះអំពីសេចក្តីសម្រេចមុនៗរបស់ខ្លួន ក្នុងការហាមឃាត់មិនឱ្យមានការថតជាខ្សែអាត់សំឡេង និង/ឬវីដេអូនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនា- ការ[30]។

## ៤. សំអាងហេតុ

11. ជាបញ្ហាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា នៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះបាន ណែនាំយ៉ាងជាក់លាក់ដល់មេធាវីការពារក្តីមិនឱ្យថតវីដេអូជនជាប់ចោទ នៅក្នុងបន្ទប់ឃុំខ្លួន ខាងក្រោមសាលសវនាការឡើយ។ បន្ទាប់មក មេធាវីការពារក្តីបានជូនដំណឹងដល់អង្គជំនុំជម្រះថា អ្នកគ្រប់គ្រងសំណុំរឿងរបស់ខ្លួននឹងស្ថិតនៅជាមួយជនជាប់ចោទ នៅក្នុងបន្ទប់ឃុំ ខ្លួនខាងក្រោមសាលសវនាការដើម្បីធ្វើកំណត់ហេតុ។ តាមពិតអ្នកគ្រប់គ្រងសំណុំរឿងបាន ថតខ្សែអាត់សំឡេងមួយចំនួនក្នុងរយៈពេលពីរថ្ងៃ រួមទាំងការសន្ទនាជាមួយក្រុមគ្រូពេទ្យដែល មានភារកិច្ចពិនិត្យ ព្យាបាល និងថែទាំ ជនជាប់ចោទ ដោយគ្មានការយល់ព្រមច្បាស់លាស់ពីពួកគាត់ និងមិនបានដាក់សំណើឱ្យបានសមស្របជូនអង្គជំនុំជម្រះឡើយ [31] ។ អង្គជំនុំជម្រះចាត់ទុកវិធីសាស្ត្ររបស់មេធាវីការពារក្តីចំពោះបញ្ហានេះថា ជាកំហុសឆ្គងមួយផងដែរ អនុលោម តាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង ហើយកំហុសឆ្គងនេះមិនគួរកើតមានឡើងទៀតឡើយ។

12. ដូចដែលសហព្រះរាជអាជ្ញាកត់សម្គាល់រួចហើយ ខ្លឹមសារនៃសំណើរបស់មេធាវីការពារក្តី គឺជាសំណើសុំប្រមូលភស្តុតាងផ្ទាល់ខ្លួន ទាក់ទិននឹងសម្បទារបស់ជនជាប់ចោទក្នុងការចូលរួម សវនាការ។ អង្គជំនុំជម្រះរំឭកដល់ភាគីនានាថា ក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ច្រាន ចោលជាមុននូវការស៊ើបអង្កេតនានាដែលធ្វើឡើងដោយភាគីទាំងនោះ។ ដោយពិចារណាលើការចោទប្រកាន់របស់មេធាវីការពារក្តីដែលបានលើកឡើងថា "អំណះអំណាងណាមួយផ្ទុយពី ទស្សនៈរបស់មេធាវីការពារក្តី សបញ្ជាក់អំពីការមិនទទួលស្គាល់ភារកិច្ច និងកាតព្វកិច្ចរបស់ មេធាវីការពារក្តី" និងថា ការហាមឃាត់មិនឱ្យមានការថតខ្សែអាត់សំឡេង និង/ឬវីដេអូជនជាប់ចោទ គឺជាការបង្កើត "ឡើងនូវចម្ងល់ថាហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងសម្រេចជ្រើស

---

[28] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥-២០។

[29] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣-២៦។

[30] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧។

[31] វាបង្ហាញថា មានការយល់ព្រមតែមួយផង ដែលមេធាវីការពារក្តីបានយកមកធ្វើជាសំអាង ដើម្បីថតការសន្ទនាលើកក្រោយៗទៀត។

00879267



យកភាពស្រពិចស្រពិល ជាជាងភាពច្បាស់លាស់ទៅវិញ” នោះ នាពេលនេះអង្គជំនុំជម្រះនឹងដោះស្រាយបញ្ហានានាដែលមេធាវីការពារក្តីប្តឹងតវ៉ា[32]។

13. អង្គជំនុំជម្រះយល់ឃើញថា ការថតខ្សែអាត់ជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ទោះបីជានៅគ្រប់ពេលវេលា ឬនៅពេលណាមួយ ដែលមេធាវីការពារក្តីសម្រេចជ្រើសយកនោះមិនមែនជាសិទ្ធិរបស់ជនជាប់ចោទដែលអង្គជំនុំជម្រះត្រូវតែអនុវត្តដូច្នេះឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីការថតខ្សែអាត់សំឡេង និង/ឬវីដេអូ មិនបានបង្កើតឡើងនូវសិទ្ធិបែបនេះឡើយ។ សេចក្តីសម្រេចនោះគ្រាន់តែអនុញ្ញាតឲ្យថតជំនួបរវាងជនជាប់ចោទជាមួយមេធាវីការពារក្តីរបស់គាត់ នៅក្នុងមន្ទីរឃុំឃាំង ដើម្បីជួយផ្តល់នូវការណែនាំដល់សហមេធាវីអន្តរជាតិរបស់ជនជាប់ចោទដែលស្ថិតនៅឯបរទេសប៉ុណ្ណោះ[33]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា “កត្តាមួយចំនួនពាក់ព័ន្ធតែចំពោះដំណើរការនីតិវិធីមុនការជំនុំជម្រះក្តី” ដែលមានន័យថា ការថតខ្សែអាត់សំឡេង និង/ឬវីដេអូ គួរត្រូវបានអនុញ្ញាតដើម្បីធានាថាជនជាប់ចោទមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួនរបស់គាត់[34]។ កាលៈទេសៈបច្ចុប្បន្ននេះគឺខុសគ្នាពីកាលៈទេសៈ ដែលអង្គបុរេជំនុំជម្រះបានសម្រេច៖ បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការគឺស្ថិតនៅខាងក្រោមសាលសវនាការផ្ទាល់តែម្តង ហើយសមាជិកក្រុមមេធាវីការពារក្តីណាក៏ដោយ អាចមានវត្តមានជាមួយនឹងជនជាប់ចោទនៅពេលណាក៏បាន និងមានខ្សែទូរសព្ទផ្ទាល់ និងសម្ងាត់ភ្ជាប់ពីបន្ទប់ ឃុំខ្លួនខាងក្រោមសាលសវនាការទៅកាន់មេធាវីរបស់ជនជាប់ចោទថែមទៀត។

14. ផ្ទុយទៅនឹងការចោទប្រកាន់របស់មេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងយល់ថា ការថតខ្សែអាត់សំឡេង និង/ឬវីដេអូជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការគឺ ពុំមែនជាសិទ្ធិមួយដែលត្រូវបានធានាដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ (“ICCPR”) នោះឡើយ។ សំអាងហេតុរបស់អង្គជំនុំជម្រះមិនបានបដិសេធ មិនឲ្យជនជាប់ចោទមានកំណត់ហេតុគ្រប់គ្រាន់អំពីថាតើគាត់មាន ឬ ពុំមានសម្បទាក្នុងការចូលរួមសវនាការនោះឡើយ។ ជនជាប់ចោទត្រូវបានវាយតម្លៃដោយអ្នកជំនាញដែលត្រូវបានតែងតាំងដោយអង្គជំនុំជម្រះថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការបាន ហើយដែលការវាយតម្លៃនោះ គឺនៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។ ជនជាប់ចោទត្រូវបាន វាយតម្លៃជាទៀងទាត់ដោយគ្រូពេទ្យដែលផ្តល់នូវកំណត់ហេតុជាលាយលក្ខណ៍អក្សរជូនដល់អង្គជំនុំជម្រះជារៀងរាល់ថ្ងៃនៃកិច្ចដំណើរការនីតិវិធីសវនាការ ហើយអង្គជំនុំជម្រះ ថ្មីៗនេះបានតែងតាំងជាថ្មីនូវអ្នកជំនាញឯករាជ្យដើម្បីពិនិត្យ

[32] សារណារបស់មេធាវីការពារក្តីស្តីពីការថតខ្សែអាត់សំឡេង និង/ឬវីដេអូ កថាខណ្ឌ ៩ និង ១៣។

[33] សាលដីការបស់ អ.ប.ជ ស្តីពីការថតខ្សែអាត់សំឡេង និង/ឬវីដេអូ កថាខណ្ឌ ៣៤-៣៥ និង ៤១។

[34] សាលដីការបស់ អ.ប.ជ ស្តីពីការថតខ្សែអាត់សំឡេង និង/ឬវីដេអូ កថាខណ្ឌ ៣៣។

ឡើងវិញអំពីសុខភាព និង សម្បទារបស់ជនជាប់ចោទ នៅក្នុងខែ មីនា ឆ្នាំ ២០១៣[35]។ ទន្ទឹមពេលគ្នានោះដែរ ក្រុមគ្រូពេទ្យដែលមានភារកិច្ចពិនិត្យ ព្យាបាល និងថែទាំ ជនជាប់ចោទអាចជម្រាបជូនអង្គជំនុំជម្រះនូវក្តីបារម្ភសំខាន់ៗ នៅពេលចាំបាច់[36]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការបដិសេធមិនអនុញ្ញាតឱ្យ មេធាវីការពារក្តីថតខ្សែអាត់សំឡេង និង/ឬវីដេអូជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការនោះ គឺមិនមែនជាការរំលោភបំពានដល់សិទ្ធិណាមួយរបស់គាត់ឡើយ រួមទាំងសិទ្ធិក្នុងការមានកំណត់ហេតុគ្រប់គ្រាន់នៃកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្ទុយទៅវិញ ការធ្វើបែបនេះអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិផ្សេងទៀតរបស់ជនជាប់ចោទ ដូចជាសិទ្ធិឯកជន និងសិទ្ធិ មានសេចក្តីថ្លៃថ្នូរ។

15. ការណ៍ដែលមេធាវីការពារក្តីអះអាងថា ការថតវីដេអូ និង/ឬថតសំឡេង ជនជាប់ចោទពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការជាការដោះបន្ទុកនោះ គឺជាការអះអាងដែលមិនអាចជឿជាក់បានឡើយ។ អត្ថន័យធម្មតានៃភស្តុតាងដោះបន្ទុកគឺជាអ្វីដែលបង្ហាញថា ជនណាម្នាក់ជាជនស្លូតត្រង់មិនបានចូលរួមប្រព្រឹត្តិបទឧក្រិដ្ឋណាមួយដែលបានចោទប្រកាន់[37]។ អង្គជំនុំជម្រះពិចារណាឃើញថា ការតវ៉ានានាដែលពាក់ព័ន្ធនឹងបញ្ហាសម្បទាក្នុងការចូលរួមសវនាការ មិនពាក់ព័ន្ធនឹងភាពស្លូតត្រង់ ឬពិរុទ្ធភាព របស់ជនជាប់ចោទទេ។ មេធាវីការពារក្តីសំអាងលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាជាភាគីមួយ និងជាពិសេសសំអាងទៅលើសេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្សនៅក្នុងយោបល់ទូទៅលេខ ៣២ ដើម្បីអះអាងថា ការថតវីដេអូ និង/ឬ ថតសំឡេង ជនជាប់ចោទនៅក្នុងបន្ទប់ឃុំខ្លួនដែលស្ថិតនៅខាងក្រោម

---

[35] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការតែងតាំងជាថ្មីនូវអ្នកជំនាញដើម្បីពិនិត្យឡើងវិញអំពីសុខភាព និង សម្បទា របស់ អៀង សារី និង នួន ជា ក្នុងអំឡុងសប្តាហ៍ទី ១១ ខែ មីនា ឆ្នាំ ២០១៣" ឯកសារ E256 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២។ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យភាគី "ធ្វើសារណាជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងវិសាលភាពនៃការវាយតម្លៃនេះត្រឹមថ្ងៃ ទី ២១ ខែ មករា ឆ្នាំ ២០១៣"។

[36] សូមមើល អនុស្សរណៈផ្ញើជូនក្រុមវេជ្ជបណ្ឌិតដែលមានភារកិច្ចពិនិត្យ ព្យាបាល និងថែទាំសុខភាព អៀង សារី នៅមន្ទីរ ឃុំឃាំង អ.វ.ត.ក ឯកសារ E238/12 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ដែលណែនាំដល់ក្រុមវេជ្ជបណ្ឌិតឱ្យក្នុងចំណោម ប្រការផ្សេងទៀត រាយការណ៍ "ជារៀងរាល់ថ្ងៃ និងដោយផ្ទាល់មកអង្គជំនុំជម្រះសាលាដំបូង មុនពេលចាប់ផ្តើមសវនាការ រៀងរាល់ព្រឹក និងបើចាំបាច់ ក្នុងពេលណាមួយនៅពេលថ្ងៃ"។

[37] វចនានុក្រម Black's Law Dictionary (បោះពុម្ពលើកទី៩) កំណត់និយមន័យនៃភស្តុតាងដោះបន្ទុកត្រង់ទំព័រ ៦៣៧ (ភាសាអង់គ្លេស) ថាជា "ភស្តុតាងដែលមានគោលបំណងបង្ហាញពីភាពស្លូតត្រង់របស់ចុងចោទក្នុងបទល្មើសណាមួយ"។ *សូមមើល*ផងដែរ វិធាន ៥៣(៤) នៃ វិធានផ្ទៃក្នុង អ.វ.ត.ក; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo*, សេចក្តីសម្រេចលើផលវិបាកនៃការមិនលាក់បាំងសម្ភារៈដោះបន្ទុកដែលមានចែងក្នុងមាត្រា ៥៤(៣)(ង) កិច្ចព្រមព្រៀង និង ការអនុវត្តន៍ដើម្បីផ្អាកការចោទប្រកាន់ជនជាប់ចោទ រួមជាមួយនឹងបញ្ហានានាផ្សេងៗទៀតដែលត្រូវបានលើកឡើងនៅឯសន្និសីទស្តីពីលក្ខន្តិកៈនាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ (សំណុំរឿងលេខ ICC-01/04-01/06), ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨ កថាខណ្ឌ ៥៩; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krstić*, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-98-33-A), ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤, កថាខណ្ឌ ១៧៨ និង ២០៤។

សាលសវនាការ និងជួយឱ្យមេធាវីការពារក្តីក្នុងការបង្ហាញថា ជនជាប់ចោទមិនមានសម្បទាក្នុងការចូលរួមសវនាការ[38]។ ក៏ប៉ុន្តែ ឧទាហរណ៍នានាដែលគណៈកម្មាធិការសិទ្ធិមនុស្សបានលើកឡើងនោះគ្រាន់តែជាការបង្ហាញថា ចម្លើយសារភាពមិនត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តទេ ហេតុដូចនេះ បញ្ហានេះវាពាក់ព័ន្ធនឹងសិទ្ធិនានាដែលខុសគ្នាទៅនឹងសិទ្ធិដែលបានលើកឡើងក្នុងករណីនៅចំពោះមុខនេះ។ មេធាវីការពារក្តីស្នើសុំឱ្យដោះស្រាយជាថ្មីចំពោះសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ទោះបីតាមពិត បញ្ហា នេះត្រូវបានវាយតម្លៃដោយផ្អែកលើការវាយតម្លៃរបស់អ្នកជំនាញវេជ្ជសាស្ត្រ ដូចដែលអង្គជំនុំ- ជម្រះបានធ្វើរួចមកហើយក្តី។

16. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការថតសំឡេង និង/ឬវីដេអូចំពោះជនជាប់ចោទ គឺមិនចាំបាច់ ឬពាក់ព័ន្ធទៅនឹងការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់អ្នកជំនាញលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការនោះទេ។ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ មិនបានបង្ហាញថា ការថតសម្លេងជនជាប់ចោទ គឺចាំបាច់សម្រាប់ការវាយតម្លៃរបស់ពួកគេនោះឡើយ។ បន្ថែម ពីលើនេះ ការវាយតម្លៃរបស់មន្ត្រីច្បាប់ ឬសមាជិកណាមួយផ្សេងទៀតរបស់ក្រុមមេធាវី ការពារក្តី អៀង សារី ឬអ្នកផ្សេងទៀតដែលមិនបានទទួលការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រ គឺមិនមានភាពពាក់ព័ន្ធចំពោះអង្គជំនុំជម្រះនោះទេ។ បុគ្គលដែលមានគុណវុឌ្ឍិសក្តិសមនឹងផ្តល់ភស្តុតាងស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការគឺអ្នកជំនាញវេជ្ជសាស្ត្រ ឯករាជ្យដែលត្រូវបានតែងតាំងដោយអង្គជំនុំជម្រះ ដែលមិនមែនជាមន្ត្រីច្បាប់ ឬសមាជិកដទៃទៀតនៃក្រុមមេធាវីការពារក្តីរបស់ អៀង សារី ទេ។ ប្រសិនបើមេធាវីការពារក្តីបារម្ភពីស្ថានភាពសុខភាពរបស់ជនជាប់ចោទនោះ សកម្មភាពដែលសមរម្យគឺត្រូវស្វែងរកការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រ ជាជាងការធ្វើតារាងសង្កេតប្រចាំថ្ងៃដូចដែលសមាជិកក្រុមមេធាវី ការពារក្តីរបស់ខ្លួនធ្លាប់បានធ្វើកន្លងមក។ ជាងនេះទៀត ការសង្កេតដែលស្នើសុំបានកត់ត្រាពីការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រដែលជនជាប់ចោទបានទទួលនៅក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ដែលរំពឹងថា អាចពាក់ព័ន្ធនឹងជីវិតឯកជនរបស់ជនជាប់-ចោទ ហើយដែលករណីថតវីដេអូ និង/ឬថតសំឡេង ដើម្បីធ្វើជាកំណត់ហេតុនោះ ជាមធ្យោបាយមួយដែលមិន ចាំបាច់នោះឡើយ។ ផ្អែកតាមសំអាងហេតុខាងលើនេះ អង្គជំនុំជម្រះសន្និដ្ឋានថា វាមិនជាការសមស្របទេដែលបង្គាប់ថា ជនជាប់ចោទគួរតែត្រូវបានថតសំឡេង និង/ឬវីដេអូ ខណៈដែលគាត់នៅក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការនោះ ទោះបីជាការថតសំឡេង និង/ឬវីដេអូ ជាប់ជាប្រចាំក្តី ឬថតនៅតាមពេលមួយចំនួន តាមការជ្រើសរើសរបស់មេធាវីការពារក្តីរបស់ខ្លួនក្តី។

---

[38] យោបល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ៣២៖ មាត្រា ១៤ សិទ្ធិមានសមភាពនៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ឯកសារលេខ CCPR/C/GC/32, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧។ *សូមមើល* កថាខណ្ឌ ៣៣៖ សម្ភារៈដោះបន្ទុក "គួរតែត្រូវបានយល់ថា រួមមានមិនត្រឹមតែសម្ភារៈដែលបង្ហាញពីភាពស្លូតត្រង់ប៉ុណ្ណោះទេ តែក៏រួមមានភស្តុតាងផ្សេងទៀតដែលអាចជួយការពារក្តីបានដែរ (ឧ. ការបង្ហាញថា ការសារភាពដែលមិនមែនធ្វើឡើងដោយស្ម័គ្រចិត្ត)"។

17. សរុបមក អង្គជំនុំជម្រះបដិសេធការអះអាងរបស់មេធាវីការពារក្ដីដែលថា ជនជាប់ចោទ អៀង សារី មានសិទ្ធិទទួលបានការថតសំឡេង និង/ឬវីដេអូ នៅក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ មិនថាជាការថតជាប់ជាប្រចាំ ឬជាការថតនៅតាមពេលមួយចំនួននោះទេ ឬសំណើណាមួយក្នុងចំណោមសំណើនានារបស់ខ្លួនដែលសមស្របនៅក្នុងកាលៈទេសៈទាំងនេះទេ។

## ផ្អែកលើសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង៖

**បដិសេធ** សំណើរបស់មេធាវីការពារក្ដីដែលសុំថតវីដេអូ និង/ឬថតសំឡេងជនជាប់ចោទពីបន្ទប់ឃុំខ្លួនដែលស្ថិតនៅពីក្រោមសាលសវនាការ។

**តម្កល់** ការសន្និដ្ឋានរបស់អង្គជំនុំជម្រះកាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដែលថា អង្គជំនុំជម្រះអាចបង្គាប់ឱ្យជនជាប់ចោទចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការ តាមរយៈមធ្យោបាយសោតទស្សន៍សមស្រប ពីបន្ទប់ឃុំខ្លួនដែលស្ថិតនៅពីក្រោមសាលសវនាការ នៅពេលដែលវត្តមានរបស់គាត់ក្នុងបន្ទប់សវនាការអាចនឹងផ្ទុយពីផលប្រយោជន៍វេជ្ជសាស្ត្រ និង/ឬ ពីកិច្ចដំណើរការនីតិវិធីសវនាការ ដោយឆាប់រហ័ស។

**តម្កល់** ដីកាសម្រេចរបស់ខ្លួន ចុះថ្ងៃទី ០៧ និងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ ដែលហាមឃាត់មិនឱ្យមេធាវីការពារក្ដីដាក់បញ្ចូលខ្សែអាត់ថតវីដេអូ និង/ឬ ថតសំឡេង ឬសេចក្ដីអង្កេតលើជនជាប់ចោទ នៅបន្ទប់ឃុំខ្លួននៅពីក្រោមសាលសវនាការទៅក្នុងសំណុំរឿង។

ភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៣

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

និល ណុន